របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងារ
ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២១

ថ្ងៃអង្គារ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១

អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

មាតិកា

១ សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២ សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

៣ សមិទ្ធផលការងារខែកក្កដា ឆ្នាំ២០២១

៤ បញ្ហាប្រឈម

៥ ទិសដៅអនុវត្តបន្ត

១

សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង

- ឯកឧត្តមទេសរដ្ឋមន្ត្រី បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់ អ.ជ.ប.ជ.អ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយថ្នាក់ដឹកនាំរបស់ អ.ជ.ប.ជ.អ និងបានផ្តល់អនុសាសន៍ជាប្រចាំពីនីតិវិធីឆ្លើយតបនឹងមេរោគអេដស៍ និងដំងឺអេដស៍ ព្រមទាំងលើកទិសដៅផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្នែកក្នុង ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្នែកក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ជា ផលា

១-សកម្មភាពទាក់ទងនឹងសជណ២១៣

ការងារួម

- បានធ្វើបទបង្ហាញក្នុងកិច្ចប្រជុំប្រចាំឆមាសទី១ឆ្នាំ២០២១នៃក្រុមឥស្សរជនឆ្នើមថ្នាក់ជាតិ។
- បានស្នើសុំយោបល់ដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ស្តីពី គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ការចុះបេសកកម្មក្នុងដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍ និងការប្រើប្រាស់គម្រោង LHSS/USAID និង DFAT ។
- បានរៀបចំឯកសារបណ្តុះបណ្តាល FoNPAM/ DFONPAM
- បានចូលរួមប្រជុំជាមួយ HACC, FoNPAM/DFoNPAM, UNAIDS, LHSS, EpiC, NCHADS

ឯកឧត្តម ជា ផលា

២- សកម្មភាពលើកគម្រោងមូលនិធិសកល

ការអនុវត្តគម្រោងមូលនិធិសកលបច្ចុប្បន្ន

- បានដឹកនាំការប្រជុំស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងផែនការវិនិយោគ និងផែនការអភិវឌ្ឍឃុំ/សង្កាត់ (CDP/ CIP)។
- បានចុះបំពេញការងារនៅ NCHADS។
- បានចូលរួមប្រជុំPR-TRT
- ដឹកនាំនិងគ្រប់គ្រងសកម្មភាពនៅក្នុងគម្រោង NAA SSI HIV Grant 2021-2023។
- បានចូលប្រជុំ CCC OCលើកទី២។

៣-សកម្មភាពជាមួយដៃគូអភិវឌ្ឍ

៣.១-UNAIDS

- បានរៀបចំសុន្ទរកថាជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** និងបានចូលរួម Meeting on HIV Estimates Dissemination and 2025 Targets។
- បានចូលរួមប្រជុំ សម្របសម្រួលការរៀបចំផែនការគម្រោង DFAT។
- បានចូលរួមជា Co-Chair of DFAT Steering Committee។
- បានចូលរួមប្រជុំ និងផ្តល់យោបល់ដល់ក្រុមការងារកាត់ចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

៣-សកម្មភាពជាមួយដៃគូអភិវឌ្ឍ

៣.២- អង្គការ USAID

- បានពិភាក្សាជាមួយ LHSS/ USAID និងមន្ត្រីបច្ចេកទេសអគ្គលេខាធិការដ្ឋាន ក្នុងរៀបចំការចុះអភិបាលកិច្ចនៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។
- បានផ្តល់បទសម្ភាសន៍ ស្តីអំពីHIV/AIDS and Universal Health Coverage in Cambodia and ASEANពីសេសលើការងារ PrEP និងDrug Resistance in Cambodia។
- បានពិភាក្សាជាមួយ មន្ត្រីបច្ចេកទេសនៃគម្រោង Social and behavior change communication។

៤-សកម្មភាពផ្សេងៗ

- បានចូលរួមជាគណៈអធិបតីជាមួយមន្ត្រីរសុខាភិបាលរាជធានីភ្នំពេញនិងសាលាសង្កាត់ទួលសង្កែ និងអង្គការ HACC នៅក្នុង Key Populations and PLHIV។
- បានចូលរួមកិច្ចប្រជុំ Research របស់អង្គការ IOM។
- បានចូលរួមកិច្ចប្រជុំក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកបសេដ្ឋ។
- បានបង្រៀនវគ្គគ្រប់គ្រង និងភាពជាអ្នកដឹកនាំ (ជំនាញទន់/បញ្ញាអារម្មណ៍ Soft Skills/ Emotional Intelligence)។
- បានចូលរួមប្រជុំនៅ។ក្នុងCambodian Non Communicable Diseases Alliance

លោកជំទាវ ស៊ឹម ខេងខាំ

- តាមដានព័ត៌មាន និងព្រឹត្តិការណ៍ផ្សេងៗដែលទាក់ទងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។
- បានតាមដាន របាយការណ៍សង្ខេប និងព្រឹត្តិការណ៍ផ្សេងៗ តាមប្រព័ន្ធតេឡេក្រាម។
- ចូលរួមកិច្ចប្រជុំប្រចាំខែកក្កដា ឆ្នាំ២០២១ តាមវីដេអូ កម្មវិធី Zoom ។
- បានសហការជាមួយអគ្គលេខាធិការដ្ឋាន ក្នុងការធ្វើផែនការប្រតិបត្តិឆ្នាំ២០២០-២០២៣ ស្តីពីការបញ្ជ្រាបយេនឌ័ររបស់ អ.ជ .ប.ជ.អ។
- បានផ្ញើគម្រោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ(AOP)២០២១ ស្តីពីការទប់ស្កាត់ អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣។

ឯកឧត្តម ស៊ឹម គឹមសៃន

- បានពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែកក្កដារបស់ថ្នាក់ដឹកនាំ។
- បានពិនិត្យ និងផ្តល់យោបល់ទៅលើរបាយណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗ សម្រេចបានរយៈពេល៥ឆ្នាំ (២០១៧-២០២១)។
- បានអាននូវសេចក្តីណែនាំស្តីពី "ការបន្តអនុវត្តយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។
- បានស្វែងយល់នូវបច្ចុប្បន្នភាពស្តីពីការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២០ ដែលរៀបចំដោយ NAA និង UNAIDS។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមបន្តការងារនានាដែលចាត់តាំងដោយឯកឧត្តមប្រធាន។
- ត្រៀមបន្តតាមដានការអនុវត្តផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០២០ របស់ក្រសួងធម្មការ និងសាសនា ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ឯកឧត្តម តែង គន្ធី

- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ពិនិត្យរបាយការណ៍៦ខែដើមឆ្នាំដែលរៀបចំដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិនិត្យ និងតាមដានកិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារក្រុមបុរសរួមភេទជាមួយបុរស និងស្ត្រីភេទ តាមរយៈរបាយការណ៍របស់ក្រុមការងារលេខាធិការដ្ឋាន។

ឯកឧត្តម ជា ពៅ

- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកក្កដា។
- បន្តតាមដានស្ថានភាពវិវត្តន៍នៃជំងឺកូវីដ១៩ និងវិធានការណ៍នានា របស់ក្រសួងសុខាភិបាល។
- បានពិនិត្យតារាងសង្ខេបដែលដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបច្ចុប្បន្នភាពស្ថានភាពនៃការរាលដាល និងការឆ្លើយតបមេរោគអេដស៍ឆ្នាំ២០២០។
- បានពិនិត្យសេចក្តីព្រាងរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗ សម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧- ២០២១) ។

ឯកឧត្តម ជា ពៅ (ត)

- បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ៩ដង ត្រឹមថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- តាមដានករណីឆ្លង Covid-19 នៅតាមបណ្តាខេត្តជាប់ព្រំដែន និងវិធានការនានា របស់ក្រសួងសុខាភិបាល ។

សំណូមពរ ៖

ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទាំងអស់ ដែលបានចុះបំពេញការងារ សិក្ខាសាលា កិច្ចប្រជុំផ្សេងៗ ជួយផ្តល់អត្ថបទព័ត៌មានខ្លី ភ្ជាប់ជាមួយរូបភាព ដើម្បីយកមកផុសក្នុងFacebook ។

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមប្រជុំអន្តរក្រសួងលើការងារបង្កើតកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលពី២០២២ដល់២០២៤ (PIP)។
- ចូលរួមប្រជុំអន្តរក្រសួងលើការងារពិនិត្យវឌ្ឍនភាពពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩ ដល់២០២៣។
- ចូលរួមប្រជុំ ថ្នាក់ដឹកនាំប្រចាំខែពិនិត្យលទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២១
- ចូលរួមត្រៀមការប្រជុំពិនិត្យលទ្ធផលនៃការធ្វើការប៉ាន់ប្រមាណនិន្នាការអេពីដេមីនៃមេរោគអេដស៍ និងការផ្សព្វផ្សាយនូវសេចក្តីថ្លែងការនយោបាយនៃសន្និបាតអង្គការសហប្រជាជាតិ។
- ចូលរួមប្រជុំក្រុមការងារគ្រប់គ្រងមូលនិធិ ក្នុងផែនការអភិវឌ្ឍកម្មវិធីវិនិយោគឃុំ សង្កាត់ គម្រោង LHSS និងគម្រោងជំនួយទីភ្នាក់ងារអូស្ត្រាលី។
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ដល់មន្ត្រីបច្ចេកទេស អ.ជ.ប.ជ.អ។

ឯកឧត្តម រស់ សីលវ៉ាត់ (ឥ)

- ចូលរួមប្រជុំក្រុមការងារគ្រប់គ្រងមូលនិធិពិនិត្យការយល់ដឹងរបស់មន្ត្រីបច្ចេកទេសស្តីពីទស្សនវិស័យប្រើប្រាស់បណ្តាញក្រុមប្រជាជនងាយរងគ្រោះ និងអ្នកផ្ទុកមេរោគអេដស៍ (ហ្វុនប៉ាម/ឌីហ្វុនប៉ាម)។
- ផ្តល់ធាតុចូលដល់ សេចក្តីព្រាងរបាយការណ៍វឌ្ឍនាភាពវិស័យអេដស៍សម្រាប់គណៈរដ្ឋមន្ត្រី។
- ចូលរួមប្រជុំថ្នាក់ដឹកនាំប្រចាំខែកក្កដា ឆ្នាំ២០២១។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមការងារធ្វើសេចក្តីថ្លែងការអង្គការសហប្រជាជាតិមកអនុវត្តនៅថ្នាក់ជាតិ។
- ចូលរួមតាមដានលទ្ធភាពអនុវត្តការងារក្រោមគម្រោងមូលនិធិសាកល។
- ចូលរួមពិនិត្យការវិវត្តលើការងារបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

ឯកឧត្តម ហោ ប៊ុនឡេង

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមធ្វើបទបង្ហាញស្តីពី "បច្ចុប្បន្នភាពនៃការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា" ជូនក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។
- បានរៀបចំឯកសារបណ្តុះបណ្តាលប្រចាំសប្តាហ៍ដល់មន្ត្រី និងបុគ្គលិកអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ស្តីពី "វិធីសាស្ត្រក្នុងការចងក្រងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធិផលស្តីពីការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍"។
- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមពិនិត្យ និងកែសម្រួលរបាយការណ៍ "កិច្ចប្រជុំក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិលើកទី១ឆ្នាំ២០២១ និងលោកទិសដៅ៦ខែចុងឆ្នាំ២០២១" ។

ឯកឧត្តម ហោ ប៊ុនឡេង (ត)

- បានជួយចូលរួមពិនិត្យ និងផ្តល់យោបល់ទៅលើរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៨-២០២១ ឆ្លើយតបទៅនឹងដំងឺអេដស៍ជូនទៅទីស្តីការគណរដ្ឋមន្ត្រី។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងដំងឺអេដស៍
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងដំងឺអេដស៍
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការដ្ឋាន។
- បានចូលរួមកិច្ចប្រជុំប្រចាំខែកក្កដា។
- បានជួយចូលរួមពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងាររយៈពេល៥ឆ្នាំ (២០១៧-២០២១)។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

២ សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការ

- ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីបច្ចុប្បន្នភាពស្ថានភាពនៃការរាលដាល និងការឆ្លើយតបមេរោគអេដស៍ឆ្នាំ២០២០ (Cambodia Epidemic and Response Update 2020) ដែលបានរៀបចំដោយអង្គការ UNAIDS និងផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ។
- ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ចូលរួមកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារប្រចាំខែកក្កដា និងលើកទិសដៅខែសីហា របស់ អ.ជ.ប.ជ.អ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ។
- ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ពិភាក្សារៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១) របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត តាមលិខិតលេខ៣៧៥ សជណ.សរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ទីស្តីកាគណៈរដ្ឋមន្ត្រី និងរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនពាក់កណ្តាលអាណត្តិរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨-២០២១។

អគ្គលេខាធិការ

- ព្រឹកថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋានអំពី "ចំណេះដឹង និងជំនាញជាមូលដ្ឋានក្នុងការអនុវត្តវិធីសាស្ត្រវិទ្យាសាស្ត្រសរសេរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការ" បន្ត ដែលបង្រៀនដោយ **ឯកឧត្តម ហោ ប៊ុនឡេង** អនុប្រធាន អ.ជ.ប.ជ.អ. តាមប្រព័ន្ធ Zoom
- រសៀលថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ចូលរួមអធិបតីបើកកិច្ចប្រជុំផ្លស់ប្តូរបទពិសោធន៍អំពីការទទួលបានសេវាអេដស៍ និងសុខភាពបន្តពូជក្នុងបរិការណ៍កូវីដ-១៩ ក្នុងចំណោមយុវជនងាយរងគ្រោះ និងអ្នកផ្ទុកមេរោគអេដស៍ ដែលរៀបចំដោយអង្គការខាន់ណា។
- រសៀលថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ផ្តល់កិច្ចសម្ភាសជាមួយ Phnom Penh Post អំពីស្ថានភាព និងភាពជោគជ័យរបស់ប្រទេសកម្ពុជាក្នុងការឆ្លើយតបមេរោគអេដស៍ ដោយសុំបញ្ជាក់ពីបច្ចុប្បន្នភាពស្ថានភាពនៃការរាលដាល និងការឆ្លើយតបមេរោគអេដស៍ឆ្នាំ២០២០ (Cambodia Epidemic and Response Update 2020) ដែលបានរៀបចំដោយអង្គការ UNAIDS និងផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** កាលពីថ្ងៃទី២ ខែសីហា។

អគ្គលេខាធិការ

- ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. លើរបៀបវារៈដូចខាងក្រោម៖

✓ ការពិនិត្យ និងពិភាក្សាលើការប៉ាន់ស្មានអំពីមេរោគអេដស៍ (Cambodia Epidemic and Response Update 2020) ដែលបានប្រកាសក្នុងកិច្ចប្រជុំផ្សព្វផ្សាយក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេរដ្ឋមន្ត្រី កាលពីថ្ងៃទី២ ខែសីហា

✓ ការរៀបចំតារាងសង្ខេបព័ត៌មានមេរោគអេដស៍ឆ្នាំ២០២០ (Cambodia HIV/AIDS at a Glance in Cambodia 2020)

✓ ការរៀបចំធ្វើផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២ (Work Plans for National AIDS Authority Secretariat 2022)។

- ព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន **អំពី** "ចំណេះដឹង នៃជំនាញទន់ (Soft Skills)" ដែលបង្រៀនដោយ **ឯកឧត្តមអនុប្រធាន អ.ជ.ប.ជ.អ.** ទទួលបន្ទុកបច្ចេកទេស តាមប្រព័ន្ធ Zoom។

អគ្គលេខាធិការ

- រសៀលថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។
- រសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំពិភាក្សាអគ្គលេខាធិការដ្ឋាន ស្តីពីមគ្គុទេសភាពក្នុងបរិការណ៍នៃការរាលដាលមេរោគកូវីដ-១៩ ទូទាំងពិភពលោក (Leadership in the Context of COVID-19 Pandemic)។
- ព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំពិភាក្សាអគ្គលេខាធិការដ្ឋាន៖

✓ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សង្ខេបស្តីពីសកម្មការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១) ជូនរាជរដ្ឋាភិបាល

✓ពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ឆ្នាំ២០២២។

- រសៀលថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំឯកសារបណ្តុះបណ្តាលអង្គការសង្គមស៊ីវិលលើការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។
- ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន អំពី "ចំណេះដឹង នៃជំនាញទន់ (Soft Skills)" បន្ត ដែលបង្រៀនដោយ **ឯកឧត្តមអនុប្រធាន អ.ជ.ប.ជ.អ.** ទទួលបន្ទុកបច្ចេកទេស។

អគ្គលេខាធិការ

- ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសជាមួយក្រសួងផែនការអំពីការនីតិវិធីនៃការផ្តល់អត្តសញ្ញាណកម្មក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ជាបុគ្គលនៅកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍។
- ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំរួមប្រចាំខែអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ.

✓បទបង្ហាញស្តីពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ ដូចមានចែងក្នុងអនុក្រឹត្យលេខ១០៩

✓ការងារតួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដូចមានចែងក្នុងច្បាប់អេដស៍ និងអនុក្រឹត្យលេខ១០៩

- ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន **អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
- ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន **អំពី** "ចំណេះដឹង នៃជំនាញទន់ (Soft Skills)" ដែលបង្រៀនដោយ **ឯកឧត្តមអនុប្រធាន អ.ជ.ប.ជ.អ.** ទទួលបន្ទុកបច្ចេកទេស តាមប្រព័ន្ធ Zoom។
- នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំពិភាក្សាអំពីសៀវភៅប្រតិបត្តិការ ក្នុងការផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅសហគមន៍ (Community-Based Anti-retroviral Therapy Delivery Operations Manual) ចូលរួមធ្វើបទបង្ហាញពីអង្គការ KHANA តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។

អគ្គលេខាធិការ

- ព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៨ ប្រចាំខែសីហា

✓"កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ" ដោយ **លោក ឈួ បញ្ញា** ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម និងជាប្រធានលេខាធិការដ្ឋានអនុគណៈកម្មាធិការសុខុមាលភាពសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

✓"បញ្ហាគ្រឿងញៀន" ដោយ **ឧត្តមសេនីយ៍ទោ លឹម តុងហួត** ប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្ថារនីតិសម្បទា នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

- រសៀលថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន អំពី "ចំណេះដឹង នៃជំនាញទន់ (Soft Skills)" បន្ត ដែលបង្រៀនដោយ **ឯកឧត្តមអនុប្រធាន អ.ជ.ប.ជ.អ.** ទទួលបន្ទុកបច្ចេកទេស។

- បំពេញការងារផ្សេងៗប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន និងគោរពជូនយោបល់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** លើការងារបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ។

អគ្គលេខាធិការដ្ឋាន

- បានប្រឹងប្រែងបំពេញការងារតាមការប្រគល់ជូនពីអគ្គលេខាធិការបានយ៉ាងល្អប្រសើរ។

នាយកដ្ឋាន ផ.ត.ឥ.ស

- នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំប្រចាំខែកក្កដា ឆ្នាំ២០២១ ក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមកិច្ចប្រជុំពិភាក្សាអំពីសៀវភៅប្រតិបត្តិការ ក្នុងការផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅសហគមន៍ (Community-Based Anti-retroviral Therapy Delivery Operations Manual) ក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមានការចូលរួមធ្វើបទបង្ហាញពីអង្គការ KHANA តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- នៅព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ បានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកក្កដា ឆ្នាំ២០២១ ក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។

- បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំ និងសរសេររបាយការណ៍ ដោយមាន**ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អនុប្រធាន អ.ជ.ប.ជ.អ ជាវាគ្មិន តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងតាមអនឡាញ ដើម្បីពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំ រំកិល ២០២២-២០២៤ ដែលរៀបចំដោយក្រសួងផែនាការ តាមប្រព័ន្ធវីដេអូ Zoom។
- បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំការរៀបចំធាតុចូលសម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ ដែលរៀបចំដោយក្រសួងផែនាការ តាមប្រព័ន្ធវីដេអូ Zoom។
- បានចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការ ក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈវីដេអូ Zoom។

- បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) លើកទី១ ដោយមាន**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិន តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីភាពជាអ្នកដឹកនាំក្នុងបរិការណ៍កូវីដ-១៩ (Leadership in the Context of COVID-19) ក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តម ឈឹម យិនដាវ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈវីដេអូ Zoom។
- បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) លើកទី២ ដោយមាន**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិន តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។

- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការរៀបចំសេចក្តីព្រាងកម្មវិធីសិក្សាសម្រាប់ប្រជាជនគន្លឹះ (Curriculum Drafting of KP FONPAM/D) ក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) លើកទី៣ ដោយមាន**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិន តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- បានចូលរួមក្នុងកិច្ចប្រជុំពិសេសរបស់អគ្គលេខាធិការដ្ឋានក្រោមការដឹកនាំកិច្ចប្រជុំដោយ**ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈវីដេអូ Zoom។

- បានចូលរួមក្នុងកិច្ចប្រជុំរួមប្រចាំខែសីហា របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ឈឹម យិនដាវ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈវីដេអូ Zoom។
- បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) លើកទី៤ ដោយមាន**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិន តាមប្រព័ន្ធវីដេអូកម្មវិធី Zoom។
- បានបូកសរុបរបាយការណ៍សកម្មភាព និងសមិទ្ធផលការងារប្រយុទ្ធនឹងជំងឺអេដស៍ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែសីហា ឆ្នាំ២០២១។
- បានរៀបចំទុកដាក់ឯកសារចេញ-ចូលក្នុងនាយកដ្ឋានឱ្យមានរបៀបរៀបរយ បញ្ជូន និងតាមដានរាល់ឯកសារដែលចេញពីនាយកដ្ឋានទៅថ្នាក់ដឹកនាំត្រួតពិនិត្យ និងចុះហត្ថលេខាតាមឋានានុក្រម។

ផែនការខែបន្ទាប់

- បន្តរៀបចំ និងពិនិត្យផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន និងរបស់នាយកដ្ឋាន PMER នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២១។
- បន្តបូកសរុបរបាយការណ៍សកម្មភាព និងសមិទ្ធផលការងារប្រយុទ្ធនឹងជំងឺអេដស៍ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកញ្ញា ឆ្នាំ២០២១។
- បន្តរៀបចំទុកដាក់ឯកសារចេញ-ចូលក្នុងនាយកដ្ឋានឱ្យមានរបៀបរៀបរយ បញ្ជូន និងតាមដានរាល់ឯកសារដែលចេញពីនាយកដ្ឋានទៅថ្នាក់ដឹកនាំត្រួតពិនិត្យ និងចុះហត្ថលេខាតាមឋានានុក្រម។

នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

- បានសម្របសម្រួល និងបានធ្វើរបាយការណ៍ក្នុងកិច្ចប្រជុំរួមអគ្គលេខាធិការដ្ឋាន នៅព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២១ ចាប់ពីម៉ោង៩:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានរៀបចំលិខិតអបអរសាទរសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីដែល បានទទួលគ្រឿងឥស្សរិយយសថ្នាក់មិត្តភាព (Order of Friendship) ពីឯកឧត្តមប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀរ ពូទីន និងចាត់ចែងឱ្យផ្សព្វផ្សាយតាមទំព័រហ្វេសប៊ុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានសម្របសម្រួល និងសហការរៀបចំកិច្ចប្រជុំពិភាក្សាអំពីសៀវភៅណែនាំប្រតិបត្តិការក្នុងការផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅសហគមន៍។

- បានពិនិត្យ និងកែលម្អគម្រោងសិក្សាស្រាវជ្រាវស្តីពីការបង្កើតសន្ធានុក្រមស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២១ រួចដាក់ឆ្លងឯកឧត្តមអគ្គលេខាធិការ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១។
- បានជួយពិនិត្យ កែសម្រួល និងប្រែសម្រួលសុន្ទរកថារបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយការប៉ាន់ស្មានអំពីមេរោគអេដស៍ និងគោលដៅ ឆ្នាំ២០២៥។
- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយការប៉ាន់ស្មានអំពីមេរោគអេដស៍ និងគោលដៅ ឆ្នាំ២០២៥ តាមបណ្តាញវីដេអូ កម្មវិធី Microsoft Teams និងបានផ្ញើសុន្ទរកថាបើកឯកឧត្តមទេសរដ្ឋមន្ត្រី (ជាភាសាខ្មែរ និងអង់គ្លេស) ជូនយូអិនអេដស៍ និងសមាជិកចូលរួម នៅព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២១។
- បានសរសេរអត្ថបទកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយការប៉ាន់ស្មានអំពីមេរោគអេដស៍ និងគោលដៅ ឆ្នាំ២០២៥ ជាភាសាខ្មែរ និងអង់គ្លេស ព្រមទាំងចាត់ចែងឱ្យផ្សព្វផ្សាយតាមទំព័របណ្តាញអ៊ីនធឺណេត និងទំព័រហ្វេសប៊ុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅព្រឹកថ្ងៃទី២ ខែសីហា។

- បានជួយបន្ថែមឯកសារ លើគម្រោងសិក្សាស្រាវជ្រាវស្តីពីការបង្កើតសន្ធានុក្រមស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ ២០២១ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២១។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកក្កដា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានសរសេរអត្ថបទ កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកក្កដា ឆ្នាំ២០២១ព្រមទាំងចាត់ចែងឱ្យផ្សព្វផ្សាយតាមទំព័របណ្តាញ អ៊ីនធឺណេត និងទំព័រហ្វេសប៊ុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅព្រឹកថ្ងៃទី៣ ខែសីហា។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍អគ្គលេខាធិការដ្ឋាន នៅព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២១ ចាប់ពីម៉ោង៩:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានរៀបចំលិខិតជូនពរខួបកំណើតសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីគម្រប់៦៩ ចូល៧០ឆ្នាំ និងចាត់ចែង ឱ្យផ្សព្វផ្សាយតាមហ្វេសប៊ុក និងទំព័របណ្តាញអ៊ីនធឺណេតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងបណ្តាញព័ត៌មាន ហ្វ្រេសញូវ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១។

- បានសម្របសម្រួល និងសហការរៀបចំកិច្ចប្រជុំក្រុមគ្រប់គ្រងគម្រោង GMC ដើម្បីពិភាក្សាអំពីការរៀបចំកម្មវិធីសិក្ខាសាលាស្តីពីការធ្វើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដាក់បញ្ចូលការងារអេដស៍ នៅរសៀលថ្ងៃព្រហស្បតិ៍ ទី៥ ខែសីហា ឆ្នាំ ២០២១។
- បានសម្របសម្រួល និងសហការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំ និងសរសេររបាយការណ៍ នៅព្រឹកថ្ងៃសុក្រ ទី៦ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩ ដោយមានឯកឧត្តមវេជ្ជបណ្ឌិត **ហោ ប៊ុនឡេង** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាវាគ្មិនបណ្តុះបណ្តាល តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍អគ្គលេខាធិការដ្ឋាន នៅព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ ២០២១ ចាប់ពីម៉ោង៩:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានសម្របសម្រួល និងសហការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) នៅព្រឹកថ្ងៃអង្គារ ទី ១០ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩ ដោយមានឯកឧត្តមវេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិនបណ្តុះបណ្តាល តាមបណ្តាញវីដេអូ កម្មវិធីZoom។

- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៅរសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៣:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពី "ភាពជាអ្នកដឹកនាំក្នុងបរិការណ៍កូវីដ- ១៩ (Leadership in the Context of COVID-19)" នៅរសៀលថ្ងៃពុធ ទី១១ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៣ ដោយមានឯកឧត្តមអគ្គលេខាធិការ ជាវាគ្មិន តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានប្រមូល និងវិភាគឯកសារដាក់ក្នុងគម្រោងសិក្សាស្រាវជ្រាវស្តីពីការបង្កើតសន្ធានុក្រមស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២១ នៅថ្ងៃទី៩-១៣ ខែសីហា ឆ្នាំ២០២១ (២៨ម៉ោង)។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំប្រចាំរួមប្រចាំខែ បច្ចេកទេសប្រចាំសប្តាហ៍អគ្គលេខាធិការដ្ឋាន នៅព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធី Zoom។

- បានជួយពិនិត្យ និងកែសម្រួលរបាយការណ៍កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមិថុនា និងខែកក្កដា ឆ្នាំ២០២១ (បានទទួលពីឯកឧត្តមនាយកខុទ្ទកាល័យ នៅថ្ងៃទី១៥ ខែសីហា និងបានកែរួចបញ្ជូនទៅវិញ នៅថ្ងៃទី១៦ ខែសីហា)។
- បានសម្របសម្រួល និងសហការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills) លើកទី៣ នៅរសៀលថ្ងៃអង្គារ ទី១៧ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង២:៣០ ដោយមានឯកឧត្តមវេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិនបណ្តុះបណ្តាល តាមបណ្តាញវីដេអូ កម្មវិធីZoom។
- បានសម្របម្រួលឱ្យដំណើរការកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន MSM-TG នៅព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩ តាមបណ្តាញវីដេអូ កម្មវិធីZoom និងប្រគល់ជូនលោក សឹង ចាន់ធីម ដំនួយការបច្ចេកទេសព័ត៌មានវិទ្យាទទួលជាអ្នកសម្របសម្រួលបន្ត។
- បានសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំពិសេសអគ្គលេខាធិការដ្ឋាន នៅរសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៣:០០ ក្រោមអធិបតីភាពឯកឧត្តមអគ្គលេខាធិការ តាមបណ្តាញវីដេអូ កម្មវិធីZoom។

- បានស្រាវជ្រាវរកវាក្យស័ព្ទ ដោយធ្វើការពន្យល់ និងដាក់និយមន័យ ក្នុងគម្រោងសិក្សាស្រាវជ្រាវស្តីពីការបង្កើតសន្ធានុក្រមស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២១ នៅថ្ងៃទី១៦ ដល់២៥ ខែសីហា ឆ្នាំ២០២១។
- បានធ្វើលិខិតឆ្លើតតបឯកភាពលើស្នើសុំផ្តល់លិខិតគាំទ្រជាផ្លូវការដល់អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) និងអង្គការជៃគូ (WOMEN) ក្នុងការអនុវត្តគម្រោងបង្ការអេដស៍នៅភូមិភាគឧត្តរ ក្នុងដែនដីខេត្តមណ្ឌលគិរី និងស្ទឹងត្រែង ចាប់ពីខែសីហា ឆ្នាំ២០២១ ដល់ខែធ្នូ ឆ្នាំ២០២៣ តាមរយៈរថយន្តអប់រំសុខភាពចល័ត (Mobile Outreach) និងផ្ញើជូនទៅបុគ្គលិកអង្គការ នៅព្រឹកថ្ងៃទី២៤ ខែសីហា។
- បានសម្របសម្រួល និងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" នៅព្រឹកថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០ ដោយមានឯកឧត្តមអគ្គលេខាធិការ ជាវាគ្មិនបណ្តុះបណ្តាល តាមបណ្តាញវីដេអូកម្មវិធីZoom។

- រៀបចំផែនការវេនយាមប្រចាំថ្ងៃ និងវេនយាមប្រចាំការចុងសប្តាហ៍សម្រាប់មន្ត្រីជាប់កិច្ចសន្យា នៅខែកញ្ញា ឆ្នាំ២០២១។
- រៀបចំផែនការវេនប្រចាំការប្រចាំថ្ងៃ វេនចេញរថយន្តប្រចាំថ្ងៃ និងវេនប្រចាំការចុងសប្តាហ៍សម្រាប់អ្នកបើកបរ នៅខែកញ្ញា ឆ្នាំ២០២១។
- ពន្លឿនការងារ ១) ការរៀបចំបង្កើតរដ្ឋទេយ្យ និងបើកប្រាក់បៃសកកម្ម និង២) បង្កើតរដ្ឋទេយ្យ និងបើកប្រាក់សម្រាប់រៀបចំកិច្ចប្រជុំ និងសិក្ខាសាលា។
- បានរៀបចំលិខិត និងសំណុំឯកសារដំឡើងថ្នាក់ ហានន្តរស័ក្តិឆ្នាំ២០២១ ដើម្បីស្នើសុំដំឡើងក្នុងឆ្នាំ២០២២ ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំនួន៣៤នាក់។
- បានរៀបចំឯកសារស្នើសុំដំឡើងហានន្តរស័ក្តិថ្នាក់ និងហានន្តរស័ក្តិកិត្តិយស ជូនលោក ហាង វិបុល ជាការលើកទឹកចិត្តនៃកិច្ចចូលនិវត្តន៍នៅឆ្នាំ២០២២។

- បានរៀបចំឯកសារចាំបាច់ផ្សេងៗ ដើម្បីផ្តល់ជូនមន្ត្រីជាប់កិច្ចសន្យាសម្រាប់ជូនភ្ជាប់ចាក់វ៉ាក់សាំង ដូសទី៣ ដូសជំរុញ តាមការណែនាំរបស់ក្រសួងសុខាភិបាល នាថ្ងៃទីចាប់ពីថ្ងៃទី៥ដល់៧ ខែកញ្ញា ឆ្នាំ២០២១ នៅមន្ទីរពេទ្យកុមារជាតិ។
- តាមដានឯកសារស្នើសុំឡើងកាំប្រាក់របស់ថ្នាក់ដឹកនាំចំនួន០៣រូប និងមន្ត្រីចំនួន១៨រូប ដែលបានស្នើឡើងកាលពីថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្រសួងសុខាភិបាល។
- បានរៀបចំ និងបានត្រួតពិនិត្យឯកសាររដ្ឋទេយ្យ ចំនួន៣៨ច្បាប់ (បណ្ណចំណាយ បណ្ណស្នើសុំថវិកា និងវិក័យបត្រ)។
- បានរៀបចំឯកសារចំណាយរដ្ឋទេយ្យបុរេប្រទាន ដែលទទួលបានការឯកភាពពីថ្នាក់ដឹកនាំដើម្បីបោះពុម្ពផ្សាយអាណត្តិទូទាត់។
- បានរៀបចំបញ្ចូលឯកសាររដ្ឋទេយ្យចូលក្នុងបេឡាក្នុងដៃប្រចាំខែសីហា និងធ្វើរបាយការណ៍បេឡាប្រចាំសប្តាហ៍ ខែសីហា ឆ្នាំ២០២១។

- បានរៀបចំអាណត្តិស្នើសុំទូទាត់ថ្លៃផ្គត់ផ្គង់ ការបោះពុម្ពសៀវភៅអំពីវិស័យអេដស៍ ប្រចាំឆ្នាំ២០២១ ជូនក្រុមហ៊ុន កុលវឌ្ឍន: ត្រេឌីងគ្រុប។
- បានរៀបចំអាណត្តិស្នើសុំទូទាត់ថ្លៃផ្គត់ផ្គង់ប្រេងឥន្ធន: និងប្រេងរំអិល ប្រើប្រាស់ ប្រចាំឆ្នាំ២០២១ ជូនក្រុមហ៊ុន កម្ពុជាតេលា។
- បានរៀបចំអាណត្តិស្នើសុំទូទាត់ថ្លៃប្រើប្រាស់ទឹករបស់អ.ជ.ប.ជ.អ ពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២១ កក្កដា ឆ្នាំ២០២១ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។
- បានចុះលេខអាណត្តិចូលក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ស្តីពីការស្នើសុំទូទាត់ថ្លៃប្រើប្រាស់ទឹករបស់អ.ជ.ប.ជ.អ ពីថ្ងៃ ទី០៤ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។
- បានរៀបចំអាណត្តិស្នើសុំទូទាត់ថ្លៃផ្គត់ផ្គង់ការជួសជុលរថយន្តចំនួន ០៦គ្រឿង របស់អ.ជ.ប.ជ.អ ឆ្នាំ២០២១ ជូនក្រុមហ៊ុន ប៊ុល ឆេងឡាង ភីស៊ីអិល ខូ អិលធីឌី។

- បានរៀបចំលិខិត និងឯកសារស្នើសុំគោលការណ៍ធានាចំណាយលើគម្រោងសិក្សាស្រាវជ្រាវស្តីពីការបង្កើតសន្ធានុក្រមស្តីពីមេរោគអេដស៍ និងដំងឺអេដស៍ ឆ្នាំ២០២១ ដែលមានថវិកា ៨០លានរៀល ហើយបានទទួលការឯកភាពពីឯកឧត្តមទេសរដ្ឋមន្ត្រី នៅថ្ងៃទី១៧ ខែសីហា។
- បានពិនិត្យនិងអនុម័តការកែតម្រូវលើស្នើសុំទូទាត់ទូរស័ព្ទអចល័ត និងការប្រើប្រាស់ថាមពលអគ្គិសនីតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។
- បានរៀបចំឯកសារចំណាយរដ្ឋទេយ្យបុរេប្រទាន និងបានបោះពុម្ពផ្សាយអាណត្តិស្នើសុំទូទាត់ ចំនួន៤០លានរៀល (រួចរាល់នៅថ្ងៃទី២៤ ខែសីហា)។
- បានពិនិត្យ និងអនុម័តលើកិច្ចសន្យាចំនួន៣ស្តីពីការបោះពុម្ពសៀវភៅវិស័យអេដស៍ ទិញប្រេងឥន្ធនៈ និងជួសជុលរថយន្ត តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។
- រង់ចាំរបាយការណ៍សវនកម្មរបស់អគ្គាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានចាប់ផ្តើមចុះមកធ្វើអធិការកិច្ចហិរញ្ញវត្ថុអាជ្ញាធរជាតិប្រយុទ្ធនឹងដំងឺអេដស៍ សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ និងឆ្នាំពាក់ព័ន្ធ តាំងពីចុងខែធ្នូ ឆ្នាំ២០២០។

- បានពិនិត្យ និងបានចុះហត្ថលេខាលើការចំណាយថវិកាជំនួយមូលនិធិសកល (Global Fund) ចំនួន ៥ច្បាប់។
- បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុថវិកាជំនួយមូលនិធិសកល (GlobalFund) ក្នុងខែកក្កដា ឆ្នាំ២០២១។
- បានឆ្លើយឆ្លងការងារជាមួយជនបង្គោល ខាងទំនាក់ទំនងរបស់មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច លោក Elden Chamberlain អំពីការបញ្ចប់គម្រោងនៅកម្ពុជា និងផ្ទេរទៅប៉ាពូអាស៊ីណូវែលហ្គីណេ។
- បានផ្តល់បទសម្ភាសន៍អំពីយុទ្ធសាស្ត្រក្នុងការប្រាស្រ័យទាក់ទង នៅក្នុងមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិចជាមួយទីប្រឹក្សាបច្ចេកទេសហ្វីលីពីន (Luchi Flores និង Tessa Torre) នៅរសៀលថ្ងៃទី២៤ ខែសីហា ចាប់ពីម៉ោង៤ ដល់៥ល្ងាច។

ផែនការសកម្មភាពខែបន្ទាប់

- តាមដានការងារប្រចាំសប្តាហ៍ ដើម្បីពិនិត្យមើលការងារដែលបានអនុវត្តកន្លងមក និងដាក់ផែនការអនុវត្តបន្តក្នុងខែកញ្ញា ឆ្នាំ២០២១។ ក្នុងនោះនឹងពិនិត្យមើល ១) ការជានានិរន្តរភាពការងារដោយការធ្វើការងារពីចម្ងាយ និង២) កិច្ចការផ្សេងៗ។
- សម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំស្តីពីផលប៉ះពាល់នៃការឆ្លងរាលដាលកូវីដ-១៩ក្នុងសហគមន៍លើការធ្វើតេស្តឈាមរកមេរោគអេដស៍ (Impact of COVID-19 Community Outbreak on HIV Testing) នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៦ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩:០០ ដោយមានលោកវេជ្ជបណ្ឌិត ទេព ណាវុធ ជាវាគ្មិនធ្វើបទបង្ហាញ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- រៀបចំឱ្យលោក សឹង ចាន់ធីម អ្នកជំនួយការព័ត៌មានវិទ្យា ធ្វើការសម្របសម្រួលក្នុងកិច្ចប្រជុំស្តីពីការរំឭកអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩:០០ តាមបណ្តាញវីដេអូ កម្មវិធីZoom។

- សម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែសីហា ឆ្នាំ២០២១ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១ ចាប់ពីម៉ោង៩:០០ តាមបណ្តាញវីដេអូ កម្មវិធីZoom។
- សម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែសីហា នៅព្រឹកថ្ងៃអង្គារ ទី៣១ ខែសីហា ឆ្នាំ២០២១ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមបណ្តាញវីដេអូ កម្មវិធី Zoom។
- ចាត់ចែងការចុះបញ្ជីបេឡាសាច់ប្រាក់ក្នុងធនាគារ និងក្នុងដៃសម្រាប់ខែកញ្ញា។
- បន្តតាមដាន និងដោះស្រាយឯកសារដែលកំពុងបន្តនីតិវិធីហិរញ្ញវត្ថុរួមមាន ៖ ១) ការរៀបចំសំណើបង្កើត និងបើក ប្រាក់បៃសកកម្ម តាមប្រកាសលេខ ០៩៩សហវ.ប្រក។

នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

- បានរៀបចំប្រជុំប្រចាំខែក្នុងនាយកដ្ឋាន១លើក (តាមរយៈវីដេអូ) ដើម្បីបន្តរៀបចំផែនការរបស់នាយកដ្ឋានលើកផែនការសកម្មភាពសម្រាប់អនុវត្តខែបន្ទាប់ និងពង្រឹងការៈកិច្ចទទួលខុសត្រូវ របស់មន្ត្រីនៅក្នុងនាយកដ្ឋាន។
- មន្ត្រីក្នុងនាយកដ្ឋានបានបន្តធ្វើការប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ ដើម្បីបានព័ត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM- TG, FEW និងការអនុវត្ត PrEP។
- មន្ត្រីក្នុងនាយកដ្ឋានបានធ្វើការតាមដានពីការអនុវត្តផែនការប្រយុទ្ធនឹងជំងឺអេដស៍ តាមក្រសួង ស្ថាប័ន ថ្នាក់ខេត្ត ស្រុក និងអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធ។
- នាយកដ្ឋាន បានប្រជុំរៀបចំផែនការនាយកដ្ឋាន សម្រាប់អនុវត្តសកម្មភាព ឆ្នាំ២០២១ បានបន្តពិនិត្យផែនការសកម្មភាព ជាអាទិភាពរបស់នាយកដ្ឋាន បានបន្តលើកផែនការសកម្មភាពសម្រាប់គម្រោង GF របស់នាយកដ្ឋាន (ត្រីមាសទី៣ និងទី៤ ឆ្នាំ២០២១)។

- ប្រធាននាយកដ្ឋាន និងមន្ត្រី បានចូលរួមប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ និងប្រចាំខែ ក្រោមការដឹកនាំប្រជុំ ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រីប្រធាន និង ឯកឧត្តម អគ្គលេខាធិការ។
- នាយកដ្ឋានបានបន្តរៀបចំនិងពិនិត្យឡើងវិញ លើប្លង់មេរៀន សម្រាប់ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការដាក់បញ្ចូលផែនការប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ។
- នាយកដ្ឋានបានចូលរួមប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋាន (តាមរយៈវីដេអូរ)
- នាយកដ្ឋានបានបន្តត្រៀមរៀបចំ និងសម្របសម្រួល ជាមួយថ្នាក់ខេត្ត (កំពង់ស្ពឺ) និងក្រសួងដែលពាក់ព័ន្ធដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលកម្មវិធីអេដស៍ ក្នុងផែនការរបស់ថ្នាក់ឃុំ សង្កាត់ និងក្រសួង ស្ថាប័ន (ចំនួន៥)។
- នាយកដ្ឋាន បានបន្តតាមដានការអនុវត្ត សជណ ២១៣ (គោលដៅទី៣) ជាមួយ LHSS តាមដានវឌ្ឍនភាព នៃការអនុវត្តយុទ្ធសាស្ត្រទី១ (យុទ្ធសាស្ត្រ បង្ការ) របស់ NSP-V និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព (វិធានការទី៧)។

- នាយកដ្ឋានបានរៀបចំប្រជុំក្រុមការងារបច្ចេកទេស MSM-TG, FEW ជាមួយដៃគូពាក់ព័ន្ធ តាមរយៈវីដេអូរ ក្រោមការដឹកនាំប្រជុំដោយ **ឯកឧត្តម ឈឹម យិនដារ៉ែត** អគ្គលេខាធិការ អ.ជ.ប.ជ.អ។
- លោកប្រធាននាយកដ្ឋាន បានចូលរួមស្តាប់បទបង្ហាញស្តីពីការសិក្សាស្រាវជ្រាវ នៃការផ្តល់សេវាថែទាំ អ្នករស់នៅជាមួយមេរោគអេដស៍ ក្នុងសហគមន៍ របស់អង្គការ KHANA តាមរយៈវីដេអូរ។
- នាយកដ្ឋានបានរៀបចំរបាយការណ៍កិច្ចប្រជុំផ្សេងៗសម្រាប់អគ្គលេខាធិការដ្ឋាន ថ្នាក់ដឹកនាំ និងដៃគូ។

ផែនការសកម្មភាពខែបន្ទាប់

- បន្តអនុវត្ត និងលើកផែនការរបស់នាយកដ្ឋាន សម្រាប់ត្រីមាសទី៣ និងទី៤ ឆ្នាំ២០២១ (ថវិកាជាតិ និង មូលនិធិសកល)
- បន្តរៀបចំប្រជុំបច្ចេកទេស និងប្រជុំប្រចាំត្រីមាស នៃក្រុមការងារ MSM/TG និង FEW
- បន្តពង្រឹងមន្ត្រីក្នុងនាយកដ្ឋានក្នុងការទទួលខុសត្រូវ តួនាទី ភារៈកិច្ច
- បន្តរៀបចំការងារបច្ចេកទេសសម្រាប់ការចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍ ក្នុងផែនការឃុំ សង្កាត់ របស់ថ្នាក់ខេត្ត
- បន្តការងារតាមដានទិន្នន័យក្រុមប្រជាជនគន្លឹះ
- បន្តចុះពិនិត្យស្ថានភាព នៃការឆ្លើយតបទៅនឹងជំងឺអេដស៍ ក្នុងផែនការឃុំ សង្កាត់ ការអនុវត្ត សជណ ២១៣ នៅថ្នាក់ខេត្ត

- បន្តរៀបចំនិងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងផែនការសម្រាប់ថ្នាក់ខេត្ត(ឃុំ សង្កាត់) និងថ្នាក់ ក្រសួង (ចំនួន៣)។
- បន្តរៀបចំកិច្ចប្រជុំប្រចាំត្រីមាសស្តីពី CIP-CDP,MCPI-DD សម្រាប់ថ្នាក់ខេត្តប្រឈមមុខខ្ពស់ នៅភ្នំពេញ
- មន្ត្រីនាយកដ្ឋានបន្តតាមដានវឌ្ឍនភាព ផែនការយុទ្ធសាស្ត្រទី១ អង្គការពាក់ព័ន្ធ និង សជណ ២១៣ (វិធានការទី៣) តាមការប្រជុំបែងចែកភារកិច្ចទទួលខុសត្រូវ។
- នាយកដ្ឋានបន្តត្រៀមរៀបចំ និងសម្របសម្រួល ជាមួយថ្នាក់ខេត្ត (កំពង់ស្ពឺ) និងក្រសួងដែលពាក់ព័ន្ធ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលកម្មវិធីអេដស៍ ក្នុងផែនការរបស់ថ្នាក់ឃុំ សង្កាត់ និងក្រសួង ស្ថាប័ន។
- នាយកដ្ឋានបន្តតាមដានការអនុវត្ត សជណ ២១៣ (គោលដៅទី៣) និងតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រទី ១ (យុទ្ធសាស្ត្រ បង្ការ) របស់ NSP-V ។

ការយកដាន ទាក់ទង និងចលនាប្រតិពត្តិការ

- រៀបចំប្រជុំស្តីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅART Site ដើម្បីផ្តល់ប័ណ្ណសមធម៌
- បានបញ្ចប់របាយការណ៍កិច្ចប្រជុំពេញអង្គលើកទី១ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១
- សម្របសម្រួលនីតិវិធីរដ្ឋបាលស្នើសុំហត្ថលេខាថ្នាក់ដឹកនាំលើលិខិតស្នើសុំការគាំទ្រ សម្រាប់អនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រាជធានី ខេត្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ របស់វិទ្យស្ថានជាតិសុខភាពសាធារណៈ បង្ហាញដោយឯកឧត្តម **ទា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស ជាវាគ្មិនបណ្តុះបណ្តាល។
- បានចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់អគ្គលេខាធិការ ក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ឈឹម យិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈវីដេអូ Zoom។
- បានចូលរួមផ្តល់ធាតុចូលលើរបាយការណ៍រីកចំរើនធៀបសូចនាករសម្រាប់ (២០១៧ ២០២១) ជូនទីស្តីការគណៈរដ្ឋមន្ត្រី
- បានផ្តល់ធាតុចូលលើការរៀបចំផែនការសកម្មភាពឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន៥៧ចំណុច ស្តីពីរបាយការណ៍ជាតិលើកទី៦ ក្នុងការអនុវត្តអនុសញ្ញាស៊ី ដ នៅកម្ពុជា សម្រាប់របាយការណ៍លើកទី៧ ឆ្នាំ២០២៣។

- ចូលរួមផ្តល់ធាតុចូលលើសៀវភៅប្រតិបត្តិក្នុងការផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅសហគមន៍
- ចូលរួមជាមួយអង្គភាពលទ្ធកម្មក្នុងការប្រគល់ និងទទួលសៀវភៅ MCPI SOP និងសៀវភៅ M&E
- រៀបចំប្រជុំប្រចាំខែក្រុមប្រឹក្សាបច្ចេកទេសលើកទី៧
- ចូលរួមផ្តល់ធាតុចូលសម្រាប់រៀបចំផែនការប្រតិបត្តិរបស់អង្គការ LHSS
- ចូលរួមផ្តល់ធាតុចូលសម្រាប់ការរៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល(២០១៧-២០២៣)
- ចូលរួមផ្តល់ធាតុចូលសម្រាប់សកម្មភាពលម្អិតថវិកា ការតាមដាន វាយតម្លៃ ទស្សទានការឆ្លើយតបមេរោគអេដស៍បែបវិមជ្ឈការ និងវិសហមជ្ឈការជាមួយអង្គការ LHSS
- ចូលរួមប្រជុំជាមួយ NCHADS តាមអនឡាយ ស្តីពីការពិភាក្សាលម្អិតលើសកម្មភាពដើម្បីស្នើសុំថវិកាពីគម្រោងDFAT
- ចូលរួមប្រជុំគណៈកម្មាការគ្រប់គ្រងមូលនិធិសកលដើម្បីពិនិត្យមើលកម្មវិធីបណ្តុះបណ្តាលឃុំ សង្កាត់ស្តីពីសមាហរណកម្មអេដស៍ក្នុងផែនការឃុំសង្កាត់។

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញទន់ភ្ជាប់ជាមួយភាពជាអ្នកដឹកនាំ និង EQ and IQ
- ចូលរួមប្រជុំអនឡាញជាមួយអង្គការខាណាស្តីពីការផ្លាស់ប្តូរបទពិសោធន៍អំពីការទទួលសេវាអេដស៍ និងសុខភាពបន្តពូជក្នុងបរិបទកូវីដ-១៩ក្នុងចំណោមយុវជនងាយរងគ្រោះ និងអ្នករស់នៅជាមួយមេរោគអេដស៍។
- ចូលរួមផ្តល់ធាតុចូលលើការពិនិត្យមើលឡើងវិញនៃរបកគំហើញ និងអនុសាសន៍ផ្នែកសិទ្ធមនុស្ស សមភាពយេនឌ័រ និងការចូលរួមរបស់សហគមន៍។
- ចូលរួមផ្តល់ធាតុចូលលើរបាយការណ៍សង្ខេបសកម្មភាពសម្រេចបានរយៈពេល៥ឆ្នាំ(២០១៧-២០២១)។
  - ✓ ប្រជុំជាមួយក្រសួងផែនការស្តីពីបង្ហាញពីទិដ្ឋភាពទូទៅនៃនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ
  - ✓ ការរៀបចំក្រុមស្នូលសម្រាប់តាក់តែងនីតិវិធីសម្រាប់ចុះបញ្ជីអ្នកផ្ទុកមេរោគអេដស៍

ផែនការសកម្មភាពខែបន្ទាប់

- ពិនិត្យតាមដានសកម្មភាពមូលនិធិសកល
- ពិនិត្យតាមដានសកម្មភាពនាយកដ្ឋាន

៣

សមិទ្ធផលការងារ
ប្រចាំខែសីហា ឆ្នាំ២០២១

- បានចេញលិខិតណែនាំឱ្យរាជធានី ខេត្តចំនួន៤ ត្រៀមរៀបចំកៀរគរវិភាជថវិកាចំនួន**៨០.០០០.០០០រៀល** (ប៉ែតសិបលានរៀល) សម្រាប់ផែនការអនុវត្តសកម្មភាព និងឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- បច្ចុប្បន្នភាពស្ថានភាពនៃការរាលដាល និងការឆ្លើយតបមេរោគអេដស៍ឆ្នាំ២០២០ (Cambodia Epidemic and Response Update 2020)។
- បានផលិតទិន្នន័យសង្ខេបឆ្នាំ២០២០ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា (Cambodia HIV/AIDS at a Glance in 2020)។
- បានទទួលធាតុចូលពី ឯកឧត្តម លោកជំទាវអនុប្រធាន អ.ជ.ប.ជ.អ. ដើម្បីរៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(ឆ្នាំ២០១៧- ២០២១) ជូនរាជរដ្ឋាភិបាល (កាលកំណត់ ៣០ វិច្ឆិកា ២០២១)។
- បានបញ្ចប់កិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយក្រសួងផែនការ NCHADS UNAIDS និងដៃគូពាក់ព័ន្ធអំពីការរៀបចំយន្តការផ្តល់អត្តសញ្ញាណកម្មក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ជាបុគ្គលនៅកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍។
- បានសិក្សាពីផលប៉ះពាល់នៃការរាតត្បាតកូវីដ-១៩ នៅសហគមន៍លើការធ្វើតេស្តរកមេរោគអេដស៍លើប្រជាជនគន្លឹះ (NCHADS, PEPFAR, USAID, Epic)។

- បានផ្តល់ជាតុចូលសម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ ដែលរៀបចំដោយក្រសួងផែនការ
- វគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន៖
  - ចំណេះដឹង និងជំនាញជាមូលដ្ឋានក្នុងការអនុវត្តវិធីសាស្ត្រវិទ្យាសាស្ត្រសរសេររបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការ (ដោយ ឯកឧត្តម ហោ ប៊ុនឡេង អនុប្រធាន អ.ជ.ប.ជ.អ.)
  - ចំណេះដឹង នៃជំនាញទន់ (Soft Skills) ៥លើក (ដោយ ឯកឧត្តមអនុប្រធានអ.ជ.ប.ជ.អ. ទទួលបន្ទុកបច្ចេកទេស)
  - អនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់រើសអើងលើនារីភេទ (CEDAW)(ដោយលោកជំទាវអនុប្រធាន)
  - ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management)(ដោយអគ្គលេខាធិការ)

៤

បញ្ហាប្រឈម

- ការអូសបន្លាយនៃការរាតត្បាតនៃមេរោគកូវីដ-១៩ ធ្វើឱ្យប៉ះពាល់លើការធ្វើអន្តរាគមន៍ និងការប្រមូលព័ត៌មាននៃការឆ្លើយតបមេរោគអេដស៍៖
  - សកម្មភាពភាគច្រើនមិនអាចអនុវត្តបាន (ជាពិសេសមូលនិធិសកល)
  - មិនអាចចុះអភិបាលនៅមូលដ្ឋាន
  - ការងារអាទិភាពមួយចំនួនត្រូវចុះជួបអ្នកពាក់ព័ន្ធផ្ទាល់។

៥

ទិសដៅអនុវត្តបន្ត

សកម្មភាពចម្បងៗសម្រាប់ដំណាក់បន្ទាប់

- បន្តរៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១) ជូនរាជរដ្ឋាភិបាល (៣១ វិច្ឆិកា ២០២១)។
- ដឹកនាំ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការដៃគូ សង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ តាមរយៈការពិនិត្យ តាមដាន វាយតម្លៃ សម្របការងារឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ទៅនឹងការប្រយុទ្ធប្រឆាំងជាមួយកូវីដ-១៩។
- បន្តដំណើរការរៀបចំសៀវភៅប្រតិបត្តិការ ក្នុងការផ្តល់អត្តសញ្ញាណកម្មក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍នៅកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ជាមួយក្រសួងផែនការ និងអង្គការពាក់ព័ន្ធ។
- ត្រៀមរៀបចំកិច្ចប្រជុំជំរុញការអនុវត្តទីក្រុងពន្លឿនការឆ្លើយតបមេរោអេដស៍ជាមួយរាជធានី ខេត្តទាំងបួន នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១។
- ចុះអភិបាលតាមបណ្តាខេត្តនានាតាមស្ថានភាពជាក់ស្តែង។

សកម្មភាពចម្បងៗសម្រាប់ដំហានបន្ទាប់

- ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងក្រុមប្រឹក្សាបច្ចេកទេសលើសេចក្តីព្រាងប្រព័ន្ធតាមដានការអនុវត្ត សជណ ២១៣ (SorChorNor#213 Monitoring System) មុននឹងគោរពជាក់ជូនសុំការអនុម័តពីកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២១។
- បន្តជំរុញការរៀបចំផែនការសកម្មភាព ថវិកា និងអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ជាពិសេសរាជធានី ខេត្ត ពន្លឿនការឆ្លើយមេរោគអេដស៍។
- បន្តរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការឆ្លើយតបមេរោគអេដស៍នៅឃុំ សង្កាត់។
- ដំណើរការរៀបចំផែនការសកម្មភាពឆ្លើយតបមេរោគអេដស៍ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន។
- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៩។
- ជំរុញអនុវត្តសេចក្តីសម្រេចកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ. ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។
- បន្តវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋាន (អញ្ជើញអង្គការពាក់ព័ន្ធមកធ្វើបទបង្ហាញ)។
- បំពេញការងារផ្សេងៗតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។

“ប្រសិនបើទង្វើរបស់អ្នក ផ្តល់កម្លាំងចិត្តដល់អ្នកដទៃឱ្យមានការស្រមើស្រមៃកាន់តែខ្ពស់ ចេះដឹងកាន់តែច្រើន មានសកម្មភាពកាន់តែច្រើន និងក្លាយទៅជាមនុស្សដែលកាន់តែពូកែឡើង នោះអ្នកគឺជាអ្នកដឹកនាំដ៏ពិតប្រាកដមែនហើយ”

(John Quincy Adams, 6th President, 1825-1829)

សូមអរគុណ!